ទូរសព្ទមកកាន់យើងខ្ញុំតាមខ្សែទូរសព្ទឥតគិតថ្លៃ៖

**1-800-511-2300**

ឬចូលទៅកាន់៖

**dhcs.ca.gov/OPL**

ភាសាអង់គ្លេស ភាសាអេស្ប៉ាញ ភាសាអារ៉ាប់ ភាសាអាម៉ានៀ ភាសាខ្មែរ ភាសាចិនកាតាំង ភាសាហ្វាស៊ី ភាសាហិណ្ឌី ភាសាមង (Hmong) ភាសាជប៉ុន ភាសាកូរ៉េ ភាសាឡាវ ភាសាចិនកុកងឺ ភាសាប៉ាន់ចាប ភាសារុស្សី ភាសាតាហ្គាឡុក ភាសាថៃ និងភាសាវៀតណាម

(អាចទំនាក់ទំនងបាន 24ម៉ោង/7ថ្ងៃ)

**ដើម្បីទទួលបានការធ្វើតេស្តដោយឥតគិតថ្លៃសម្រាប់ពិនិត្យមើលជំងឺមហារីកដោះ និងស្បូន អ្នកត្រូវ៖**

- រស់នៅក្នុងរដ្ឋកាលីហ្វញ៉ា។
- មានអាយុគ្រប់តាមលក្ខខណ្ឌតម្រូវ។
- គ្មាន ឬមានធានារ៉ាប់រងសុខភាពដែលមានកម្រិត។
- មានការធានារ៉ាប់រងសុខភាពដោយមានសហបង់ថ្លៃ ឬប្រាក់ធានារ៉ាប់រងត្រូវបង់មុន ដែលអ្នកមិនអាចមានលទ្ធភាពបង់ប្រាក់បាន។
- មានប្រាក់ចំណូលគ្រួសារកម្រិតទាប។

## សេចក្តីថ្លែងអំពីការមិនរើសអើង

នាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វញ៉ា គោរពតាមច្បាប់សិទ្ធិពលរដ្ឋរបស់សហព័ន្ធ និងមិនរើសអើងលើមូលដ្ឋានជាតិសាសន៍ ពណ៌សម្បុរ ជាតិកំណើត អាយុ ពិការភាព ឬភេទឡើយ។

## សេវាជំនួយផ្នែកភាសា

Si habla español, usted puede conseguir ayuda para entender este documento, hablando con su proveedor de atención primaria del programa EWC o llamando al Contratista Regional de su condado. Los teléfonos del Contratista Regional se encuentran abajo. Esta asistencia lingüística es gratis.

如果您說漢語，我們可以幫助您瞭解這份文檔。請諮詢您所在地EWC附近診所或當地負責聯絡人。當地負責人電話見下文，他們會免費提供說明服務。

PLACE LABEL HERE

Every Woman Counts

**1-800-511-2300**
**dhcs.ca.gov/EWC**

© 2017 Department of Health Care Services. All Rights Reserved.

Khmer 8/2017

# យកចិត្តទុកដាក់លើស្ត្រីគ្រប់រូប

## ការថតពិនិត្យសុដន្យ និងស្បូនដោយឥតគិតថ្លៃ

## តើអ្វីទៅជាកម្មវិធី យកចិត្តទុកដាក់លើស្ត្រីគ្រប់រូប

កម្មវិធី យកចិត្តទុកដាក់លើស្ត្រីគ្រប់រូប (Every Woman Counts) ផ្តល់សេវាថតឆ្លុះពិនិត្យជំងឺមហារីកដោះ និងស្បូន និងសេវាពិនិត្យតាមដានជំងឺដោយឥតគិតថ្លៃ។ សេវាទាំងនេះ រួមមានការត្រួតពិនិត្យសុដន្យ ការថតឆ្លុះពិនិត្យសុដន្យ និងការថតពិនិត្យស្បូន ដល់ស្ត្រីដែលរស់នៅក្នុងរដ្ឋកាលីហ្វញ៉ា។

នៅពេលដែលស្ត្រីឈានចូលដល់វ័យចំណាស់ ជាពិសេសចាប់ពីអាយុ 50 ឆ្នាំឡើងទៅ ឱកាសនៃការកើតមានជំងឺមហារីកដោះ និងមហារីកស្បូនមានកម្រិតខ្ពស់។ ស្ត្រីត្រូវធ្វើការថតឆ្លុះពិនិត្យជំងឺមហារីកដោះនិងមហារីកស្បូនជាប្រចាំជាមួយវេជ្ជបណ្ឌិត។

## តើហេតុអ្វីបានជាអ្នកចាំបាច់ធ្វើការឆ្លុះពិនិត្យរកជំងឺមហារីកដោះ?

- ការពិនិត្យសុដន្យអាចឲ្យវេជ្ជបណ្ឌិតដឹង ឬពិនិត្យមើលថា តើមានការប្រែប្រួលអ្វីខ្លះចំពោះសុដន្យរបស់អ្នក។
- ការថតឆ្លុះពិនិត្យសុដន្យអាចរកឃើញជំងឺមហារីកដោះដែលតូចបំផុតដែលអ្នកឬវេជ្ជបណ្ឌិតរបស់អ្នកមិនអាចស្ទាបដឹងបាន។
- នៅពេលដែលជំងឺមហារីកដោះត្រូវបានរកឃើញទាន់ពេលវេលា វាគឺមានភាពងាយស្រួលក្នុងការព្យាបាល។

## តើអ្នកត្រូវធ្វើការថតឆ្លុះពិនិត្យរកជំងឺមហារីកសុដន្យញឹកញាប់ដែរឬទេ?

ប្រសិនបើអ្នកមានអាយុ 40 ឬចាស់ជាងនេះ សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតរបស់អ្នកអំពីពេលវេលា និងថាតើអ្នកត្រូវថតឆ្លុះពិនិត្យរកជំងឺមហារីកសុដន្យញឹកញាប់ប៉ុណ្ណា។

## កម្មវិធី យកចិត្តទុកដាក់លើស្ត្រីគ្រប់រូប ផ្តល់ជូនដោយឥតគិតថ្លៃនូវ៖

- ការពិនិត្យសុដន្យ និងការថតឆ្លុះពិនិត្យសុដន្យដល់ស្ត្រីចាប់ពីអាយុ 40 ឆ្នាំឡើងទៅ។
- ការថតឆ្លុះពិនិត្យជំងឺសម្រាប់ស្ត្រីដែលមានរោគសញ្ញានៃជំងឺដែលមានអាយុក្រោម 40 ឆ្នាំ។ (សូមមើលសញ្ញាព្រមានខាងក្រោម)
- ការថតឆ្លុះពិនិត្យស្បូនសម្រាប់ស្ត្រីអាយុ 21 ឆ្នាំឡើងទៅ។
- ការធ្វើតេស្តរួមគ្នានៃការថតឆ្លុះពិនិត្យស្បូន និងការធ្វើតេស្តរកវីរុស HPV ដល់ស្ត្រីដែលមានអាយុ 30 ឆ្នាំឡើងទៅ។
- ការធ្វើតេស្តពិនិត្យតាមដានជំងឺ ប្រសិនបើចាំបាច់។

### សញ្ញាព្រមាន និង/ឬរោគសញ្ញាមួយចំនួននៃជំងឺមហារីកដោះរួមមាន៖

- ដុំសាច់ដែលអាចស្ទាបដឹងបាន ដុំពក ឬហើមនៅក្នុងដោះ ឬក្រោមខ្លៀក
- មានការប្រែប្រួលទំហំ ឬទ្រង់ទ្រាយដោះ
- មានការប្រែប្រួលសាច់និងពណ៌ស្បែក (ស្បែកមានស្នាមខួច ស្នាមប៉ោង ឡើងពណ៌ក្រហម បែកស្រកា ឬក្រិន) សុដន្យ និងចុងសុដន្យ
- ចុងសុដន្យលឹបចូលក្នុងឬរួមចូលក្នុង
- មានខ្ទុះចេញតាមចុងសុដន្យ និង/ឬ
- ឈឺចាប់សុដន្យ។

សូមកត់សម្គាល់ថា សញ្ញាប្រមាន និង/ឬរោគសញ្ញាទាំងអស់នេះ អាចកើតមានឡើងជាមួយជំងឺដទៃទៀតក្រៅពីជំងឺមហារីកដោះផងដែរ។

**1-800-511-2300**
**dhcs.ca.gov/OPL**

## ហេតុអ្វីបានជាអ្នកត្រូវធ្វើការថតឆ្លុះពិនិត្យរកជំងឺមហារីកស្បូន?

- ការធ្វើតេស្តថតឆ្លុះពិនិត្យរកជំងឺមហារីកស្បូន រួមមានការធ្វើតេស្តពិនិត្យស្បូន និងការធ្វើតេស្តរកវីរុស HPV។
- ការធ្វើតេស្តពិនិត្យស្បូន ពិនិត្យមើលការផ្លាស់ប្តូរកោសិកានានានៅក្នុងស្បូន ដែលអាចបណ្តាលឲ្យមានជំងឺមហារីក។
- ការធ្វើតេស្តរកវីរុស HPV ពិនិត្យមើលវីរុសដែលអាចនាំឲ្យមានការផ្លាស់ប្តូរកោសិកានៅក្នុងស្បូន។
- ការព្យាបាលលើការផ្លាស់ប្តូរកោសិកាទាំងនេះ អាចការពារជំងឺមហារីកស្បូនបាន។

## តើអ្នកត្រូវធ្វើការថតឆ្លុះពិនិត្យរកជំងឺមហារីកស្បូនញឹកញាប់ដែរឬទេ?

កម្មវិធី យកចិត្តទុកដាក់លើស្ត្រីគ្រប់រូប ផ្តល់ជូនការធ្វើតេស្តពីនិត្យស្បូនដោយឥតគិតថ្លៃដល់ស្ត្រីដែលមានអាយុ 21 ឆ្នាំឡើងទៅ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានសេវានេះ និងទទួលបានការធ្វើតេស្តត្រួតពិនិត្យជារៀងរាល់បីឆ្នាំម្តង ប្រសិនបើលទ្ធផលប្រក្រតីធម្មតា។ ស្ត្រីដែលមានអាយុ 30 ឡើងទៅ អាចជ្រើសរើសធ្វើតេស្តពិនិត្យស្បូន រួមជាមួយនឹងការធ្វើតេស្តពិនិត្យរកវីរុស HPV ប្រសិនបើគាត់ចង់ពន្យារពេលនៃការថតឆ្លុះពិនិត្យរកជំងឺរហូតដល់ទៅ 5 ឆ្នាំ។ ប្រសិនបើលទ្ធផលនៃការធ្វើតេស្តទាំងពីរប្រក្រតីធម្មតា ឱកាសនៃការកើតមានជំងឺមហារីកក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខមានកម្រិតទាបបំផុត។